ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការមេគង្គ

សេចក្តីប្រកាសព័ត៌មាន

# កិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ បន្តលើកកម្ពស់ ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ក្នុងអនុតំបន់មេគង្គ

**ឯកឧត្តម សុខ ចិន្តាសោភា ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១២ នៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២៤ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ។

រដ្ឋមន្ត្រីការបរទេសនៃបណ្តាប្រទេសមេគង្គ និងកូរ៉េ បានកត់សម្គាល់ដោយពេញចិត្តចំពោះវឌ្ឍនភាពជាវិជ្ជមាន និងការអភិវឌ្ឍប្រកបដោយផ្លែផ្កា ដែលសម្រេចបានក្រោមកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ចាប់តាំងពីការបង្កើតកិច្ចសហប្រតិបត្តិការនេះនៅក្នុងឆ្នាំ២០១១ ជាពិសេសការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃផែនការសកម្មភាពឆ្នាំ២០២១-២០២៥ ស្តីពីកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងការតភ្ជាប់អនុតំបន់ លើកកម្ពស់ការប្រកួតប្រជែង កាត់បន្ថយគម្លាតអភិវឌ្ឍន៍ក្នុងចំណោមបណ្តាប្រទេសក្នុងអនុតំបន់មេគង្គ និងកសាងសហគមន៍ប្រកបដោយភាពធន់ជាងមុន។

រដ្ឋមន្ត្រីការបរទេសនៃប្រទេសសមាជិកទាំងអស់ បានអបអរសាទរចំពោះជោគជ័យនៃការរៀបចំ វេទិកាធុរកិច្ចមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១១ នៅទីក្រុងសេអ៊ូលកាលពីខែវិច្ឆិកាកន្លងទៅ ដែលកម្ពុជាបានធ្វើសហប្រធានជាមួយសាធារណរដ្ឋកូរ៉េ។ វេទិកានេះបានផ្តល់ឱកាសពេញលេញ ក្នុងការពង្រឹងភាពជាដៃគូធុរកិច្ច និងការធ្វើឱ្យកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ រវាងប្រទេសមេគង្គ និងសាធារណរដ្ឋកូរ៉េឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។ កិច្ចប្រជុំរំពឹងថា វេទិកាធុរកិច្ចមេគង្គ-សាធារណរដ្ឋកូរ៉េ ដែលឡាវ និងសាធារណរដ្ឋកូរ៉េ នឹងធ្វើជាសហប្រធាន នៅទីក្រុងវៀងចន្ទន៍នាខែក្រោយ នឹងទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855)
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

រដ្ឋមន្ត្រីការបរទេសនៃប្រទេសសមាជិកទាំងអស់ បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ដោយផ្អែកលើសសរស្តម្ភទាំងបី រួមមាន ប្រជាជន វិបុលភាព និងសន្តិភាព និងវិស័យអាទិភាពទាំងប្រាំពីរ ដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ទន្លេមេគង្គ-ទន្លេហាន ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព នាំមកនូវផលប្រយោជន៍ទៅវិញទៅមក និងវិបុលភាពក្នុងអនុតំបន់មេគង្គ។

ក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា** បានថ្លែងកោតសរសើរចំពោះតួនាទីដ៏សំខាន់របស់សាធារណរដ្ឋកូរ៉េ ដែលជាដៃគូគន្លឹះក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងអនុតំបន់ តាមរយៈជំនួយអភិវឌ្ឍន៍ផ្លូវការ និងការរួមវិភាគទានប្រចាំឆ្នាំដល់មូលនិធិសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ និង បានស្វាគមន៍ចំពោះការប្តេជ្ញាចិត្តនាពេលថ្មីៗនេះរបស់សាធារណរដ្ឋកូរ៉េ ក្នុងការបង្កើនការរួមចំណែកផ្នែកហិរញ្ញវត្ថុតាមរយៈមូលនិធិសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ រហូតដល់ ១០ លានដុល្លារ ត្រឹមឆ្នាំ២០២៧។ ទន្ទឹមនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ចំពោះសាធារណរដ្ឋកូរ៉េ ដែលបានជួយដល់ការងារសកម្មភាពមីននៅកម្ពុជា ដើម្បីបញ្ចប់ផលប៉ះពាល់អវិជ្ជមានដែលកើតឡើងដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាម សំដៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៨។

សម្រាប់ទិសដៅអនាគតនៃកិច្ចសហប្រតិបត្តិការ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីវិស័យអាទិភាពមួយចំនួន ដែលផ្តោតលើ (១) ការអភិវឌ្ឍធនធានមនុស្ស (២) ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានធម្មជាតិ (៣) កិច្ចសហប្រតិបត្តិការកសិកម្ម និងអភិវឌ្ឍជនបទ (៤) ការរួមគ្នាដោះស្រាយបញ្ហាសន្តិសុខមិនប្រពៃណី និង (៥) ការលើកកម្ពស់ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន ដែលនឹងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ននៅក្នុងអនុតំបន់។

កិច្ចប្រជុំបានបញ្ចប់ដោយមានការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកលើបញ្ហាតំបន់ និងអន្តរជាតិដែលជាក្តីកង្វល់រួម៕

ថ្ងៃអាទិត្យ ៨រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រៀងចន្ទន៍ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤